**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០១......សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង

## ស្តីពីកាតព្វកិច្ចអាករលើតម្លៃបន្ថែម (VAT)

ដើម្បីជាការក្រើនរំលឹកអំពីកាតព្វកិច្ចប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់សហគ្រាស ក្រុមហ៊ុនទាំងអស់ដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) ឱ្យបានជ្រាបថា អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាស ក្រុមហ៊ុន ដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែម គឺជាបុគ្គលដែលទទួលខុសត្រូវចំពោះមុខច្បាប់លើការប្រមូលប្រាក់អាករលើតម្លៃបន្ថែម (VAT) ពីអតិថិជន ដែលជាអ្នកប្រើប្រាស់ និងត្រូវបង់ប្រាក់អាករដែលជាប្រាក់របស់រដ្ឋទាំងនោះជូនរដ្ឋបាលសារពើពន្ធ ។ សហគ្រាស ក្រុមហ៊ុន ទាំងនោះត្រូវកំណត់និងប្រមូលប្រាក់អាករតាមអត្រា ១០ ភាគរយ នៃទឹកប្រាក់ដែលត្រូវគិតយកពីអតិថិជន ។ ក្នុងករណីដែលមិនបានបង្ហាញទឹកប្រាក់អាករលើតម្លៃបន្ថែម (VAT) នៅលើវិក្កយបត្រ ទឹកប្រាក់សរុបនៅលើវិក្កយបត្រនោះត្រូវបានចាត់ទុកថាមានរួមបញ្ចូលទាំងអាករលើតម្លៃបន្ថែម ។ បំណុលអាករលើតម្លៃបន្ថែម (VAT) មានចំនួនស្មើនឹងទឹកប្រាក់សរុបលើវិក្កយបត្រចែកនឹង ១១ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមថ្លែងសរសើរចំពោះសហគ្រាស ក្រុមហ៊ុនមួយចំនួន ដែលបានគោរពប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដោយបានប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋ ជូនរដ្ឋបាលសារពើពន្ធបានត្រឹមត្រូវ ទៀងទាត់ និងទាន់ពេលវេលា ។

ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យឃើញថាមាន សហគ្រាស ក្រុមហ៊ុន មួយចំនួនមិនទាន់គោរពបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (VAT) បានត្រឹមត្រូវនៅឡើយ ។ សហគ្រាស ក្រុមហ៊ុន ខ្លះបានប្រមូលអាករលើតម្លៃបន្ថែម (VAT) ពីអតិថិជនហើយ ប៉ុន្តែមិនបានយកប្រាក់អាករមកបង់ជូនរដ្ឋបាលសារពើពន្ធឡើយ ដោយគិបកេងយកប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋទុកជាផលប្រយោជន៍របស់ខ្លួន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ឱ្យសហគ្រាស ក្រុមហ៊ុនដែលអនុវត្តមិនបានត្រឹមត្រូវដូចបានជម្រាបជូនខាងលើ ប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលជាប្រាក់របស់រដ្ឋ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែយ៉ាងយឺតបំផុតនៅថ្ងៃទី២០ នៃខែ បន្ទាប់ពីខែដែលទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ ។ ដោយឡែកចំពោះប្រាក់អាករលើតម្លៃបន្ថែម (VAT) ដែលសហគ្រាស ក្រុមហ៊ុនមួយចំនួនបានប្រមូលពីអតិថិជនរួចហើយ ប៉ុន្តែនៅមិនទាន់បានបង់ជូនរដ្ឋទេនោះ ត្រូវរួសរាន់បង់ប្រាក់អាករលើតម្លៃបន្ថែមដែលជាប្រាក់របស់រដ្ឋនោះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅដំណាច់ខែមករា ឆ្នាំ២០០៦ នេះជាកំហិត ។ បើហួសពីរយៈពេលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងប្រើអំណាចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងផ្នែកទី៦នៃច្បាប់ស្តីពីសារពើពន្ធមានជាអាទិ៍ ការបញ្ឈប់សកម្មភាពអាជីវកម្ម ការឃាត់ទុកគណនីធនាគារ និងការទុកជាមោឃៈនូវលិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណនានា ឬក៏អាចនឹងឈានទៅដល់ការប្តឹងចោទប្រកាន់ទៅតុលាការស្តីពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក លោកស្រី ប្រធានសហគ្រាស ក្រុមហ៊ុន ដែលអនុវត្តមិនបានត្រឹមត្រូវដូចបានជម្រាបជូនខាងលើ នឹងបំពេញកាតព្វកិច្ចប្រមូលនិងបង់ប្រាក់អាករលើតម្លៃបន្ថែម(VAT) បានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា តាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន មិនខាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**